**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## រូបសញ្ញារបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញារបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ប្រើក្នុងដំណើរការការងាររបស់ខ្លួន។

**មាត្រា២ .-**

រូបសញ្ញារបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមានរូបភាពដូចតទៅ៖

- រង្វង់មូលពណ៌ខៀវអមដោយខ្សែពណ៌ក្រហមមានចារឹកជាអក្សរខ្មែរពណ៌សថា «**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**» នៅផ្នែកខាងលើនិងមានចារឹកជាអក្សរអង់គ្លេសថា «NATIONAL COMMITTEE FOR DISASTER MANAGEMENT» នៅផ្នែកខាងក្រោមតំណាងឱ្យស្ថាប័ន
- រូបមនុស្សចាប់ដៃពណ៌ខៀវជារង្វង់តំណាងឱ្យការចូលរួមទាំងអស់គ្នាលើការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញពីគ្រោះមហន្តរាយ នៅក្នុងរង្វង់មនុស្សចាប់ដៃដោយពុះចែកជាបី តំណាងមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឱ្យមានគ្រោះមហន្តរាយដូចមាន៖
  + ផ្ទៃពណ៌ផ្ទៃមេឃនិងរូបផ្ទះលិចទឹក គឺទឹកជំនន់
  + ផ្ទៃពណ៌ដីនិងដើមឈើជ្រុះស្លឹក ដីប្រេះក្រហែង គឺរាំងស្ងួត

+ ផ្ទៃពណ៌ក្រហម ជាគ្រោះមហន្តរាយបង្កឡើងដោយធម្មជាតិឬមនុស្ស និងរូបពពកមានផ្ទៃកបន្ទោរ គឺខ្យល់ព្យុះ

- ចំកណ្តាលមានរូបប្រាសាទអង្គរវត្ត ពណ៌ស លើផ្ទៃពណ៌ក្រហមព័ទ្ធដោយរង្វង់ពណ៌ខៀវ តំណាងវប្បធម៌និងភាពរុងរឿងនៃប្រជាជាតិខ្មែរ។

រូបសញ្ញាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

រូបសញ្ញារបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានប្រើដូចខាងក្រោមៈ

- ដាក់លើក្បាលលិខិតផ្លូវការរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ប្រើប្រាស់ក្នុងករណីចាំបាច់ផ្សេងៗដែលកំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០១៩

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

NATIONAL COMMITTEE FOR DISASTER MANAGEMENT